# ជំពូកទី៨

# ការសន្និដ្ឋាន និងអនុសាសន៍

Draft

# ជំពូកទី ៨
# សន្និដ្ឋាន និងអនុសាសន៍

## ៨.១ សន្និដ្ឋាន

គំរោងវិនិយោគរបស់ក្រុមហ៊ុន **SETHIKULA CO., LTD** ជាគំរោងដែលទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការវិនិយោគ លើគំរោងបង្កើតកសិដ្ឋានដាំដំណាំកសិ-ឧស្សាហកមដំណាំកៅស៊ូ ដែលជាការវិនិយោគមួយសមស្របបំផុតនៅលើទឹកដី នៃឃុំប៊ូស្រា ស្រុកពេជ្រាដា និងឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី គំរោងនេះ បានវិនិយោគលើ ផ្ទៃដីសរុប **៤.២៧៣ ហិកតា**។ ផលិតផលដែលគ្រោងផលិតក្រុមហ៊ុននឹងធ្វើការផ្គត់ផ្គង់ចំពោះទីផ្សារទាំងក្នុងស្រុក និងនាំចេញទៅក្រៅប្រទេសទៅតាមតម្រូវការទីផ្សារ។ ដោយសារដំណើរការរបស់គំរោងអាចនឹងបង្កជាហេតុអវិជ្ជមានខ្លះៗចំពោះតំបន់ដែលគំរោងតាំងនៅ ហេតុនេះគំរោងបានរៀបចំឱ្យមានជារបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងឡើង ដើម្បីសិក្សាពីកំណត់ហេតុប៉ះពាល់ជាមុន។

តំបន់វិនិយោគកសិ-ឧស្សាហកម្មនេះ ស្ថិតនៅក្នុងស្រុកពេជ្រាដា និងស្រុកអូររាំង ខេត្តមណ្ឌលគីរី ដែលជាប់ពាក់ព័ន្ធជាមួយនឹងដីឃុំចំនួន២គឺៈ (១)**ឃុំប៊ូស្រា** (២)**ឃុំដាក់ដាំ**។ ទីតាំងគំរោងតំបន់ដែនជំរកសត្វព្រៃភ្នំណាមលៀរ លើផ្ទៃដីសរុប ៤.២៧៣ហិកតា ដែលក្នុងនោះសំរាប់រយៈពេល **៩៥ ឆ្នាំ**។ ក្រុមហ៊ុននេះ ជាអ្នកវិនិយោគជនជាតិខ្មែរ គឺលោក **ខូច ផល្លាបុត្រ** ដែលមានដើមទុន ៤.០០០.០០០.០០០ **រៀល**។

ចំណាត់ថ្នាក់ទីជំរាលក្នុងតំបន់សិក្សាមានការប្រែប្រួលពី ០-៤៥ ដឺក្រេ ដែលមានកំរិតទីជំរាលមធ្យម ៥,៣៤ ដឺក្រេ នឹងមាន Standard Deviation = ៥៣៧,១១ ម៉ែត្រ។ កំរិតជំរាលត្រូវបានបែងចែកជា ៤ ចំណាត់ ថ្នាក់ធំៗ គឺ : កំរិតទីជំរាល ០-៥ដឺក្រេ ចំនួន ២.៤៥៩ ហិកតា ស្មើនឹង ៥៧,៥៥% កំរិតទីជំរាល ៥-២០ដឺក្រេ ចំនួន ១.៧១៣ ហិកតា ស្មើនឹង ៤០,០៨ % កំរិតទីជំរាល ២០-៣០ដឺក្រេ ចំនួន ៩៤ ហិកតា ស្មើនឹង ២,២០% និងកំរិតទីជំរាលចាប់ពី ៣០ដឺក្រេឡើងទៅ ចំនួន ៧ហិកតា ស្មើនឹង ០,១៧ %។

ចំណាត់ថ្នាក់ប្រភេទដី មានប្រភេទដីសំខាន់តែ ០៣ ប្រភេទ គឺ ប្រភេទដី Basic Lithosols ដែលមានផ្ទៃដីចំនួន ២.២៥៧ ហិកតា ស្មើនឹង ៥២.៨២%, ប្រភេទដី Regurs ដែលមានផ្ទៃដីចំនួន ២.០០៨ហិកតា ស្មើនឹង ៤៦.៩៩% នឹងប្រភេទដី Latosols ដែលមានផ្ទៃដី ៨ហិកតា ស្មើនឹង ០.១៨%។ ដីក្រហមបាសាល់ Latosols ជាប្រភេទដីឥដ្ឋទៅដីឥដ្ឋ-ល្បាប់ ដែលមានជីជាតិល្អ។ ស្រទាប់កសិកម្ម មានជំរៅពី ១០-២០សង់ទីម៉ែត្រ និង pH =៥.៥-៦.៨។ ដីនេះជាដីត្រូវការផ្ទស្វាតច្រើនហើយ ត្រូវនឹងដំណាំកៅស៊ូ ស្វាយចន្ទី ចេក ពោត សណ្តែក ដំណាំយកផ្លែ តែ កាហ្វេ និងព្រៃចំរុះ ប៉ុន្តែត្រូវមានវិធានការការពារការហូរច្រោះ និងភ្លើងឆេះព្រៃ។

យោងតាមសៀវភៅផែនការមេរបស់គំរោង និងតាមការសំភាសន៍ជាមួយអាជ្ញាធរពាក់ព័ន្ធ និងការចុះទៅពិនិត្យទីតាំងជាក់ស្តែង បានអោយដឹងថា គំរោងរបស់ក្រុមហ៊ុន **សេដ្ឋីកុលា** មានទីតាំងនៅក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀវ **ខេត្តមណ្ឌលគិរី ដោយមានពាក់ព័ន្ធជាមួយនឹង** ដីព្រៃតំណម ដីស្រែចំការប្រជាពលរដ្ឋ ចំនួន ៤៣៤ហិកតា. ដីរក្សាទុកនៅតំបន់ភ្នំ ចំនួន ៤៨៨ហិកតា និងដីរក្សាទុក សងខាងដងអូរ ១០០-១៥០ម៉ែត្រ ចំនួន ៤៩១ហិកតា។ ដោយយោងតាមសៀវភៅផែនការមេដដែលនេះ ចំពោះដីស្រែ-ចំការប្រជាពលរដ្ឋ ដីរក្សាទុកនៅតំបន់ភ្នំ និងដីរក្សាទុកសងខាងដងអូរ ១០០-១៥០ម៉ែត្រ ត្រូវបានកាត់ចេញពីតំបន់គំរោង (ឧបសម្ព័ន្ធ : ១-១០)។ **ដូចនេះក្រុមហ៊ុនទទួលបានដីសំរាប់ដំណើរការដាំកៅស៊ូ មានចំនួនសរុប ២.៨៦០ហិកតាប៉ុណ្ណោះ។**

ចំពោះប្រភពទឹកនៅក្នុងតំបន់គំរោងមានផ្លូវទឹកសំខាន់មួយចំនួនដូចជា : អូររេត អូរណាវ អូរឆែល អូរពោត។

ឆ្លងតាមការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង នៃគំរោងវិនិយោគដាំដើមកៅស៊ូរបស់ក្រុមហ៊ុន **SETHIKULA CO., LTD** បានបង្ហាញថា:

ផលប៉ះពាល់ចំពោះប្រជាជនដែលស្ថិតនៅក្នុងឃុំប៊ូស្រានៃស្រុកពេជ្រាដាតែប៉ុណ្ណោះ ដែលមានភូមិពាក់ព័ន្ធដូចជា ពូទឹត ពូរាំង ប៊ូស្រា ពូចារ ឡាំមេះ និងពូលុ។ ជារួមក្នុងនោះផលប៉ះពាល់ ដែលរកឃើញមានចំពោះបរិស្ថាន និងសង្គមសំខាន់ៗនៅក្នុងឃុំទាំងនោះមានដូចជា:

- ការប៉ះពាល់សតិអារម្មណ៍របស់ប្រជាជន នៅពេលដែលដឹងពីវត្តមានរបស់គំរោង
- ការប៉ះពាល់ដល់ការប្រើប្រាស់ដីរបស់ប្រជាជនដូចជា ដីអាស្រ័យផល ដីចំការបុស្ស(ដីចំការចាស់) ដីចំការវិលជុំ ដីបំរុងទុក និងដីទុកលែងសត្វគោក្របីរបស់ប្រជាពលរដ្ឋ ដែលមានទំលាប់លែងសត្វនៅក្នុងតំបន់គំរោង
- ការប៉ះពាល់ដល់ដីព្រៃតំណម និងដីព្រៃខ្មោចដែលជាតំបន់ទំនៀមទំលាប់ប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចព្នង
- អាចនឹងមានការបំពុលទឹកដោយសារសកម្មភាពរបស់គំរោង ដូចជាការហៀរកំពប់ប្រេងម៉ាស៊ីនជាដើម ហើយកត្តានេះនឹងនាំអោយមានការបំពុលដល់ខ្សែទឹកខាងក្រោម
- ការបំពុលខ្យល់ ដែលបណ្តាលមកពីសកម្មភាពឈូសឆាយ ដឹកជញ្ជូនសំភារៈ និងដំណើរការផលិតកម្មនានារបស់គំរោង
- ការរំខានដោយលេង និងរំញ័រ ដោយសារដំណើរការនានារបស់គំរោង ដូចជាការឈូសឆាយ និងសកម្មភាពដឹកជញ្ជូន ជាដើម
- ការបាត់បង់នូវមុខរបរបន្ទាប់បន្សំរបស់ប្រជាជន ដែលធ្លាប់អាស្រ័យនឹងធនធានធម្មជាតិនៅតំបន់គំរោង ដូចជា ការរកអនុផលព្រៃឈើសំរាប់ផ្គត់ផ្គង់ជីវភាពជាដើម



Draft

- ការបាត់បង់នូវប្រព័ន្ធអេកូឡូស៊ីដើមរបស់តំបន់...។

រាល់ហេតុប៉ះពាល់ដែលបានរៀបរាប់ខាងលើ គឺមកពីវិនិយោគរបស់គំរោងលើដីឯកជនរបស់រដ្ឋ ដែលប្រជាជន សត្វ និងរុក្ខជាតិក្នុងតំបន់មានការពឹងពាក់ទៅលើ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលបានត្រិះរិះពិចារណាយ៉ាងដិតដល់ពីគំរោងវិនិយោគនេះ ហើយតម្រូវឱ្យក្រុមហ៊ុននេះ មាននូវវិធានការកាត់បន្ថយផលប៉ះពាល់នានា ដែលកើតមានឡើង ដោយរៀបចំវិធានការនានាដូចជា :

- ការពិភាក្សាក្រុមជាមួយនឹងប្រជាពលរដ្ឋមូលដ្ឋាន ដែលទទួល និងអាចទទួលរងការប៉ះពាល់ពីការអនុវត្តគំរោង ដើម្បីផ្តល់ជាព័ត៌មានលំអិតស្តីពីព្រំប្រទល់គំរោង និងគោលដៅក្នុងការវិនិយោគដីសម្បទានសេដ្ឋកិច្ចនៅតំបន់នេះ
- ការរក្សាផ្ទៃដីព្រៃដែលដុះនៅតាមសងខាងដងអូរ និងប្រភពទឹក យ៉ាងហោចណាស់ ២០០ ម៉ែត្រសម្រាប់ជួយរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់
- ការឈូសឆាយដី និងប្រព្រឹត្តិនូវសម្មភាពនានា ដោយគោរពតាមគោលការណ៍របស់សៀវភៅផែនការមេ
- ការគ្រប់គ្រងកាកសំណល់នានារបស់គំរោងឱ្យបានត្រឹមត្រូវដូចជា មានកន្លែងសំរាប់ស្តុកទុកនូវកាកសំណល់រឹង រាវ សំរាប់ការពារការបាចសាចនៃកាកសំណល់ពាសវាលពាសកាល ដែលជាហេតុធ្វើឱ្យប៉ះពាល់សុខភាពកម្មករ និងប្រជាជននៅក្បែរតំបន់គំរោង
- ការដាំឈើឡើងវិញត្រង់កន្លែងដែលបានដកហូតឈើរួច នៅតាមអនុតំបន់នីមួយៗ ដោយមានការថែទាំត្រឹមត្រូវ មុនពេលប្រគល់តំបន់វិនិយោគជូនរាជរដ្ឋាភិបាលវិញ...។

ចំណែកឯផលប្រយោជន៍ដែលអាចទទួលបានពីគំរោងវិនិយោគរបស់ក្រុមហ៊ុន **SETHIKULA CO., LTD** ចំពោះសេដ្ឋកិច្ច និងសង្គមវិញមានដូចជា :

- ការជួយកាត់បន្ថយនូវសកម្មភាពកាប់ឈើដោយអនាធិបតេយ្យ
- ការជួយបញ្ឈប់នូវការរានយកដីតាមបែបអាណាធិបតេយ្យ ជាពិសេសនៅតំបន់គំរោង
- ការជួយស្តារឡើងវិញនូវតំបន់ដីព្រៃដែលរិចរិល តាមរយៈផែនការដាំដើមឈើឡើងវិញ
- ការផ្តល់នូវការងារដល់ប្រជាពលរដ្ឋខ្មែររាប់រយនាក់
- ការផ្តល់នូវជំនាញ និងបទពិសោធន៍នានាដល់កម្មករ
- ការផ្ទេរនូវចំណេះដឹង បច្ចេកវិទ្យាពីបរទេសមកដល់ប្រជាពលរដ្ឋខ្មែរ
- ការជួយសំរួលដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទាញយកផលប្រយោជន៍ពីការប្រើប្រាស់ធនធានដីឱ្យអស់លទ្ធភាព

- ការសាងសង់នូវផ្លូវគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅក្នុងតំបន់គំរោង ដូចដែលមានចែងក្នុងផែនការមេ
- ការជួយកាត់បន្ថយនូវចំណាកស្រុករបស់ប្រជាជននៅក្នុងតំបន់
- បង្កើនប្រាក់ចំណូលចូលដល់ក្រុមគ្រួសាររបស់ប្រជាជននៅក្នុងតំបន់
- ការបង្កើនចំណូលថវិការដ្ឋតាមរយៈការបង់ពន្ធ
- ការជួយបង្កើតនូវទំនាក់ទំនងសង្វាក់ផលិតកម្ម និងឧស្សាហកម្មនានា
- ការបង្កើននូវចរន្តសេដ្ឋកិច្ច និងការបង្ហាញពីទិដ្ឋភាពល្អប្រសើរក្នុងដំណើរការវិនិយោគនានាក្នុងប្រទេស...។

ស្របទៅតាមចំណុចវិជ្ជមានដែលបានរៀបរាប់ខាងលើ គំរោងជឿជាក់ថាវត្តមានរបស់គំរោងពិតជាផ្តល់ផលវិជ្ជមានយ៉ាងច្រើនចំពោះប្រជាពលរដ្ឋរស់នៅជុំវិញ និងក្រៅតំបន់ និងចូលរួមក្នុងការបង្កើនប្រាក់ចំណូលជូនជាតិ។ លើសពីនេះ គំរោងបានរៀបចំផែនការយ៉ាងត្រឹមត្រូវដើម្បីបំបាត់ ឬកាត់បន្ថយហេតុប៉ះពាល់ទាំងឡាយចំពោះបរិស្ថាន និងសហគមន៍រស់នៅជុំវិញតំបន់ឱ្យនៅកម្រិតអប្បបរមា ដែលវាជាផ្នែកមួយដែលធ្វើឱ្យភាពវិជ្ជមានរបស់គំរោងកាន់តែមានច្រើនឡើងថែមទៀត។

គំរោងក៏បានទទួលនូវយោបល់វិជ្ជមាន និងការគាំទ្រពីសំណាក់អាជ្ញាធរផងដែរ ដោយសារគំរោងនឹងផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋមូលដ្ឋានយ៉ាងច្រើន ថែមទាំងជួយដល់ការថែរក្សា ស្តារ និងការកសាងនូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន។ រីឯប្រជាជនមូលដ្ឋានវិញ មួយចំនួនមិនមានការជំទាស់នឹងគំរោងវិនិយោគទេ ប្រសិនបើគំរោងមានវិធីសាស្រ្តដោះស្រាយដីដែលប៉ះពាល់របស់ពួកគាត់បានសមស្រប និងមួយចំនួនទៀតបានធ្វើការជំទាស់ចំពោះគំរោង ( *មានបង្ហាញជូននៅក្នុងជំពូកទី ៥* )។

## ៨.២ អនុសាសន៍

ដើម្បីជៀសវាងនូវបញ្ហាដូចបានបង្ហាញខាងលើនេះ ក្រុមហ៊ុនត្រូវអនុវត្តនូវវិធានការកាត់បន្ថយហេតុប៉ះពាល់មួយចំនួន រួមមាន :

- ការរក្សាទុកផ្ទៃដីព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃជុំវិញប្រភពទឹក ក្នុងទំហំ និងចំងាយ ដែលបានណែនាំក្នុងផែនការមេ និងកិច្ចសន្យារវាងក្រុមហ៊ុន និងក្រសួងបរិស្ថាន។
- ការរក្សាទុកដីព្រៃតំណម និងព្រៃខ្មោចរបស់ប្រជាជន
- គ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេងម៉ាស៊ីន និងសំណល់ជី និងថ្នាំគីមី ឱ្យបានត្រឹមត្រូវល្អ ព្រមទាំងបង្កើនការអប់រំដល់បុគ្គលិក-កម្មករ ឱ្យចេះថែរក្សាអនាម័យ និងបរិស្ថានល្អទាំងក្នុង និងក្រៅតំបន់គំរោង និងការ

Draft

ពារសុខភាពផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ ព្រមទាំងរៀបចំឱ្យមានបន្ទប់ពិនិត្យសុខភាព និងផ្តល់ការព្យាបាលប្រកបដោយប្រសិទ្ធិភាព។

- កំណត់ពេលវេលាធ្វើការ ដោយជៀសវាងនៅពេលថ្ងៃត្រង់ និងពេលយប់ ព្រោះជាពេលវេលាសំរាករបស់ប្រជាជន និងបុគ្គលិក-កម្មករគំរោង។
- អប់រំណែនាំដល់បុគ្គលិក-កម្មករ គំរោងឱ្យចេះគោរពច្បាប់ និងផ្លាកសញ្ញាចរាចរណ៍ និងបើកបរដោយយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់។
- ផ្តល់អាទិភាពខ្ពស់ដល់ប្រជាជននៅក្នុងតំបន់ អាចធ្វើជាបុគ្គលិក-កម្មករនៅក្នុងតំបន់គំរោង តាមសមត្ថភាពដែលមាន។
- ធ្វើការថែទាំ និងជួសជុលផ្លូវគមនាគមន៍នៅក្នុងតំបន់គំរោងជាប្រចាំ ហើយត្រូវធានាថានឹងដាក់ផ្លូវទាំងនោះជាផ្លូវសាធារណៈ ដើម្បីអោយប្រជាជនអាចប្រើប្រាស់ផ្លូវនេះក្នុងការធ្វើដំណើរ និងប្រកបរបរចិញ្ចឹមជីវិតស្របច្បាប់របស់ពួកគាត់។
- ជាពិសេសនោះ គឺត្រូវដោះស្រាយឱ្យមានភាពត្រឹមត្រូវ និងសមស្រប នូវរាល់ដីធ្លីរបស់ប្រជាជនដែលមានការប៉ះពាល់។
- ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង សំរាប់រោងចក្រកែច្នៃកៅស៊ូក្រែបដាច់ដោយឡែកមួយទៀត ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ជារួម ដើម្បីឱ្យជៀសវាង ឬកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន និងសង្គមខាងលើ បន្ថែមពីលើការអនុវត្តនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ ដោយក្រុមហ៊ុនផ្ទាល់ ក្រុមហ៊ុនក៏ត្រូវអនុវត្តនូវផែនការគ្រប់គ្រងបរិស្ថាន ដោយមាននូវកម្មវិធីត្រួតពិនិត្យជាប្រចាំ ដោយមានការសហការជាមួយមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការបំពុល, នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានអភិរក្ស និងការពារធម្មជាតិនៃក្រសួងបរិស្ថាន មន្ត្រីមន្ទីរបរិស្ថាន មន្ទីរកសិកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ដែនជំរកសត្វព្រៃភ្នំណាមលៀវ និងខណ្ឌរដ្ឋបាលព្រៃឈើខេត្តមណ្ឌលគីរី អាជ្ញាធរខេត្ត ស្រុក ឃុំ និងតំណាងប្រជាជនមូលដ្ឋានខេត្តមណ្ឌលគីរី ឱ្យបានល្អ និងជានិច្ច។ ការអនុវត្តនូវផែនការគ្រប់គ្រងបរិស្ថាននេះ នឹងជួយដល់ក្រុមហ៊ុនអាចសំរេចបាននូវ ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន បានល្អត្រឹមត្រូវ និងជៀសវាងបញ្ហាវិវាទមួយចំនួន។

ជាចុងក្រោយ ក្រុមហ៊ុនសូមធានាថានឹងអនុវត្តនូវរាល់វិធានការកាត់បន្ថយ និងផែនការគ្រប់គ្រងបរិស្ថាន ដូចបានបង្ហាញក្នុងរបាយការណ៍នេះ ព្រមជាមួយនឹងសេចក្តីណែនាំផ្សេងទៀតរបស់ក្រសួងបរិស្ថាន ក៏ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង មន្ទីរ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

បានឃើញ និងឯកភាព
ថ្ងៃទី........ខែ................ឆ្នាំ ២០១១
**ក្រុមហ៊ុន សេដ្ឋីកុលា**
**នាយកក្រុមហ៊ុន**

**ឧកញ៉ា ខូវ_ឧល្លាបុត្រ**

បានឃើញ និងឯកភាព
ថ្ងៃទី........ខែ................ឆ្នាំ ២០១១
**ក្រុមហ៊ុន ហ្គ្រីនអ៊ីនវ៉ាយរ៉ិនមិន គ្រុប**
**នាយកក្រុមហ៊ុន**

**ហាស ណារ៉ូ**

Draft

# ឯកសារយោង

Draft

# ឯកសារយោង

- *ច្បាប់ស្តីពីព្រៃឈើ*, ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦, ២០០២ / ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

- *ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ*, ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩, ២០០១/ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- *ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា*, ព្រះរាជក្រមលេខ នស/រកម/០៦០៧ /០១៦, ២០០៨/ក្រសួងធនធានទឹក និងឧតុនិយម

- *ច្បាប់ភូមិបាល*, ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤, ២០០១/ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

- *ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ*, ក្រសួងបរិស្ថាន, ២៤ វិច្ឆិកា ១៩៩៦ /ក្រសួងបរិស្ថាន

- *ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ*, ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧, ២០០៨ ក្រសួងបរិស្ថាន

- *ច្បាប់ស្តីពីជីវសុវត្ថិភាព*, ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦, ២០០៨ ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ ៧២ អនក្រ.បក, ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩, *ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះ ពាល់បរិស្ថាន* / ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ ២៧ អនក្រ.បក, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩, *ស្តីពីការត្រួតពិនិត្យការបំពុលទឹក* /ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ ៣៦ អនក្រ.បក, ថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩, *ស្តីពីការគ្រប់គ្រងសំណល់រឹង* /ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ ៤២ អនក្រ.បក, ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០០, *ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសម្លេង* /ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ ១៤៦ អនក្រ.បក, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥, *ស្តីពីសម្បទានដីសេដ្ឋកិច្ច*

- អនុក្រឹត្យលេខ ៣៧ អនក្រ.បក, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩, *ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព*

- *គោលការណ៍ណែនាំទូទៅសម្រាប់ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន*, ០២ កញ្ញា ២០០៩/ក្រសួងបរិស្ថាន

- *ផែនការបរិស្ថានជាតិ*, ១៩៩៨-២០០២ /ក្រសួងបរិស្ថាន

- *ស្ថិតិឧតុនិយមខេត្តមណ្ឌលគិរី*, ២០០៦-២០០៨ /ក្រសួងធនធានទឹក និងឧតុនិយម ( មន្ទីរធនធានទឹក និងឧតុនិយម ខេត្តមណ្ឌលគិរី)

- *សៀវភៅផែនការមេរបស់ក្រុមហ៊ុន SETHIKULA Co., Ltd*, ២០០៩/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- *ផែនទីភូគព្ភសាស្ត្រប្រទេសកម្ពុជា* , ២០០២ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)

- *ផែនទីព្រំប្រទល់ខេត្តនៃប្រទេសកម្ពុជា*, ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)

- *ផែនទីព្រំប្រទល់ស្រុកនៃប្រទេសកម្ពុជា*, ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)

Draft

- *ផែនទីព្រំប្រទល់ឃុំនៃប្រទេសកម្ពុជា*, ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- *ផែនទីទីរួមខេត្តនៃប្រទេសកម្ពុជា*, ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- *ផែនទីទីរួមស្រុកនៃប្រទេសកម្ពុជា*, ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- *ផែនទីទីរួមឃុំនៃប្រទេសកម្ពុជា* , ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- *ផែនទីទីរួមភូមិនៃប្រទេសកម្ពុជា*, ២០០៥ /ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- *ធនធានគំរបព្រៃឈើកម្ពុជា* , ២០០៦ /ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- *សៀវភៅថនិកសត្វប្រទេសកម្ពុជា, ២០០០*
- *មគ្គុទ្ទេសក៍នៅតំបន់វាលភ្លោះទៅស្គាល់សត្វស្លាបនៃប្រទេសកម្ពុជា*, ២០០៣
- *សត្វព្រៃនៅកម្ពុជា និងការគ្រប់គ្រង*, ២០០៥ / មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ
- *Geographic Information System Data Set of Cambodia*, 2002 / JICA
- *Cambodia Soil Classification (*Charles D. Crocker), 1962 / N.A.

Draft